ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ១០៣៣

ចុះថ្ងៃទី ០៦_១២_២០១០

សាលដីកា

លេខ : ៤១ "ក្រ.III.ស"

ចុះថ្ងៃទី ១៥_០៦_២០១២

# នាមរាស្ត្រប្រជាខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

**********

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២១_០៥_២០១២ ដោយមានសមាសភាពដូចខាងក្រោមៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ១០៣៣ ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១០ ដែលមានៈ

១- ជនជាប់ចោទឈ្មោះ [redacted] ពៅ ភេទស្រី អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរលក់ពូក កើតនៅស្រុកព្រះស្តេច ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នផ្ទះ [redacted] ក្រុម៤ ភូមិ១ សង្កាត់អូរឫស្សី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ក្រៅឃុំ។

២- ជនជាប់ចោទឈ្មោះ [redacted] ធឿន ភេទស្រី អាយុ ២៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ កើតនៅភូមិអូររំចេក ស្រុកស្ទោង ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នផ្ទះ [redacted] ភូមិ១ សង្កាត់អូរឫស្សី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ក្រៅឃុំ។

**<u>ជាប់ចោទពីបទៈ</u> បង្ករបួសស្នាមដោយចេតនា** ប្រព្រឹត្តនៅផ្ទះលេខ២៣១Eo ផ្លូវលេខ២១៧ សង្កាត់ អូរឫស្សី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោស តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **វិសិដ្ឋារម្យ** ភេទស្រី អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ២៣៣Eo ផ្លូវលេខ២១៧ សង្កាត់អូរឫស្សីទី ២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ច័ន្ទធីតា** ភេទស្រី អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរនិស្សិត ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ២៣៣Eo ផ្លូវលេខ ២១៧ ក្រុម៤ ភូមិ១ សង្កាត់អូរឫស្សី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

## ៦ដំណើររឿងមានដូចតទៅៈ

កាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង ៦ល្ងាច នៅចំណុចមុខផ្ទះលេខ ២៣១Eo ផ្លូវលេខ ២១៧ សង្កាត់អូរឬស្សី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានករណីបង្ករបួសស្នាមមួយកើតឡើងដែលបង្កឡើងដោយជនល្មើស ឈ្មោះ [redacted] ពៅ ឈ្មោះ [redacted] ធឿន បានវាយបង្ករបួសស្នាមគ្នាជាមួយឈ្មោះ [redacted] ច័ន្ទនីតា ឈ្មោះ [redacted] **វិសិដ្ឋារម្យ** បណ្តាលឱ្យរងរបួសរៀង១ខ្លួន។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ ៦៧ "ខ" ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ឱ្យឈ្មោះ

ក- ឈ្មោះ [redacted] **វិសិដ្ឋារម្យ** ភេទស្រី អាយុ ៤៣ឆ្នាំ ជាតិខ្មែរ

ខ- ឈ្មោះ [redacted] **ច័ន្ទនីតា** ភេទស្រី អាយុ ២១ឆ្នាំ ជាតិខ្មែរ

គ- ឈ្មោះ [redacted] **សុចារិទ្ធ** ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ

ឃ- ឈ្មោះ [redacted] **ម៉ារីណា** ភេទស្រី អាយុ ៣៩ឆ្នាំ ជាតិខ្មែរ រួចខ្លួនពីបទចោទ **បង្ករបួសដោយចេតនា** ប្រព្រឹត្តនៅផ្ទះលេខ ២៣១Eo ផ្លូវលេខ ២១៧ សង្កាត់អូរឬស្សីទី ២ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៩ តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ផ្តន្ទាទោសលើឈ្មោះ [redacted] **ពៅ** ភេទស្រី អាយុ ២៥ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] **ធឿន** ភេទស្រី អាយុ ២៣ឆ្នាំ ជាតិខ្មែរ ក្នុងម្នាក់ៗកំណត់រយៈពេល ០១ឆ្នាំ "មួយឆ្នាំ" តែទោសនេះត្រូវព្យួរធម្មតា ពីបទ **បង្ករបួសដោយចេតនា** ប្រព្រឹត្តនៅផ្ទះលេខ ២៣១Eo ផ្លូវលេខ ២១៧ សង្កាត់អូរឬស្សី ២ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៩ បទល្មើសមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ១០៧ នៃក្រម ព្រហ្មទណ្ឌ។

៣- បង្គាប់ឱ្យឈ្មោះ [redacted] **ពៅ** និងឈ្មោះ [redacted] **ធឿន** រួមគ្នាសងសំណងថ្លៃថ្នាំព្យាបាលរបួស និងជំងឺចិត្តជាទឹកប្រាក់ចំនួន ៥០០ ០០០រៀល "ហាសិបម៉ឺនរៀល" ទៅឈ្មោះ [redacted] **វិសិដ្ឋារម្យ** និងឈ្មោះ [redacted] **ច័ន្ទនីតា**។ ការទាមទារលើស ពីនេះត្រូវច្រានចោល។

៤- សាលក្រមនេះជំនុំជម្រះជាសារណៈនៅថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **វិសិដ្ឋារម្យ** និងឈ្មោះ [redacted] **ច័ន្ទនីតា** និងមេធាវីការពារជនជាប់ចោទ លោកមេធាវី [redacted] **វណ្ណារិទ្ធ** និងមេធាវីលោក [redacted] **សុភ័ក្ត្រ** កំបាំងមុខឈ្មោះ [redacted] **ពៅ** ឈ្មោះ [redacted] **ធឿន** ឈ្មោះ [redacted] **រីណា** និងឈ្មោះ [redacted] **សុចារិទ្ធ** បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៦០៧ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] **ពៅ** និងឈ្មោះ [redacted] **ធឿន** ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៧ "ខ" ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១០ របស់សាលាដំបូង រាជធានីភ្នំពេញ ត្រង់ចំណុចទី ១ (ក និង ខ) ចំណុចទី ២ និងចំណុចទី ៣ នៃសេចក្តីសម្រេច។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **វិសិដ្ឋារម្យ** និងឈ្មោះ [redacted] **ច័ន្ទនីតា** បានឆ្លើយ នៅសាលាដំបូងរាជធានីភ្នំពេញ។

ជនជាប់ចោទឈ្មោះ [redacted] **ពៅ** ឆ្លើយថា: ខ្លួនប្ដឹងឧទ្ធរណ៍មកនេះ ព្រោះខ្លួនមិនសុខចិត្ត ដោយសារខ្លួនអត់បានវ៉ៃគេទេ គឺខ្លួនការពារខ្លួន ព្រោះគេវ៉ៃខ្លួនស្ទុះវ៉ៃដល់ក្នុងផ្ទះ ទាំងម៉ែទាំងកូន ហើយខ្លួនអត់បានខ្វាចមុខគេទេ។ សំណូមពរខ្លួន សុំមិនបង់ប្រាក់សំណងទេ។

ជនជាប់ចោទឈ្មោះ [redacted] **ធឿន** ឆ្លើយថា: ខ្លួនប្ដឹងឧទ្ធរណ៍មក ព្រោះខ្លួនមិនសុខចិត្ត ខ្លួនអត់បានវ៉ៃគេទេ គឺគេចូល មកវ៉ៃខ្លួនមុន ហើយខ្លួនអត់បានខ្វាចគេទេ។ សំណូមពរ ខ្លួនសុំមិនបង់ប្រាក់សំណងទេ។

**សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ**

បណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] **ពៅ** និងឈ្មោះ [redacted] **ធឿន** ធ្វើឡើងត្រឹមត្រូវតាមច្បាប់ ហើយសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ដូច្នេះ សុំតម្កល់សាលក្រមនេះទុកជាបានការដដែល។

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

**សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:**

១- បណ្ដឹងឧទ្ធរណ៍លេខ ៦០៧ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] **ពៅ** និងឈ្មោះ [redacted] **ធឿន** ជាជនជាប់ចោទ ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- តាមចម្លើយជនជាប់ចោទថា ពួកខ្លួនទាំងពីរនាក់នេះជាអ្នកបម្រើការលក់ដូរនៅផ្ទះអ្នកស្រី [redacted] **ម៉ារីណា** បើករបរលក់ពូក នៅថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង ៦ល្ងាច មានភ្ញៀវចូលមកទិញពូកនៅផ្ទះអ្នកស្រី [redacted] **ម៉ារីណា**. លុះភ្ញៀវវិលត្រឡប់វិញ ក្រោយពីទិញពូកបាន ស្រាប់តែដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **វិសិដ្ឋារម្យ** និងនាង [redacted] **ច័ន្ទនីតា** ស្រែកជេរខ្លួន និងស្ទុះមកវាយពួកខ្លួនដួលទាំងពីរនាក់។

៣- តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីថា កាលពីថ្ងៃកើតហេតុនោះខ្លួនទៅសួរអ្នកស្រី **ម៉ារីណា** ពីករណីអ្នកបម្រើទាំង ២នាក់ របស់ឈ្មោះនេះបានទៅហៅភ្ញៀវពីក្នុងផ្ទះរបស់ខ្លួន។ ពេលនោះជនជាប់ចោទបានចង្អុលមុខខ្លួន និងកូន ស្រីខ្លួន. ពេលនោះកូនស្រីខ្លួនក៏ប្រាប់ថា កុំចង្អុលមុខ ភ្លាមនោះជនជាប់ចោទក៏ចាប់កអាវ **ច័ន្ទនីតា** ហើយវាយ

ជាច្រើនដៃ និងខ្មៅក្រញៀមុខដាច់ស្នាម ។

៤- មានពិរុទ្ធលើជនជាប់ចោទ ពីបទ **បង្ករបួសស្នាមដោយចេតនា** ប្រព្រឹត្តនៅផ្ទះលេខ ២៣៣Eo ផ្លូវលេខ ២១៧ សង្កាត់អូរឬស្សីទី ២ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៩ បទល្មើសមានចែង និងឱ្យ ផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥- សំអាងហេតុ និងសេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ៦៧ "ខ" ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ គួរតម្កល់ទុកជាបានការ ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៦០៧ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ពៅ និង [redacted] **ធឿន** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៧ "ខ" ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទទាំង ២នាក់ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីពេលនេះទៅ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់ មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី 04 ខែ 06 ឆ្នាំ ២០១៤
ក្រឡាបញ្ជី